# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

**ព្រះរាជក្រឹត្យ លេខ នស/រកត/០៨៩៨/៥៧**

**យើង**

**ព្រះបាទសម្តេចព្រះនរោត្តម សីហនុ**

**ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា**

**តែងតាំង**

**លោក លី សាយ ឃាង**

**ជា**

**ខុកញ៉ា**

ព្រះហស្តលេខា

**នរោត្តម សីហនុ**

===========

# II- ក្រុមប្រឹក្សាធម្មនុញ្ញ

## សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៨

**សេចក្តីសំរេច លេខ ០៤ កបធ/សសរ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

-យល់ឃើញថា : ពាក្យបណ្តឹងរបស់គណបក្សហ្វ៊ុនស៊ិនប៉ិច លេខ ១៦២/៩៨ ន.ត.ក. ចុះថ្ងៃទី១១ ខែ សីហា ឆ្នាំ ១៩៩៨ ជំទាស់នឹងសេចក្តីសំរេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ២០៨-១៧១៣/៩៨ គជប ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៨ដែលបានដិតសេចបណ្តឹងលេខ ០៣៧/៩៨ ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៩៨ ស្តីពីភាពមិនប្រក្រតីនៃការរាប់សន្លឹកឆ្នោត ដោយសំអាងថា គណៈកម្មការឃុំរៀបចំការបោះឆ្នោត ឃុំបន្ទាយក្រាំង ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង

បានហែកសន្លឹកឆ្នោត ដែលប្រជាពលរដ្ឋគូសអោយគណបក្ស ហ៊្វុនស៊ិនប៉ិច មួយសន្លឹក ជាពាក្យបណ្តឹងមិនត្រឹមត្រូវទេ ។

-ដោយយល់ឃើញថា : ការស៊ើបអង្កេតរបស់ក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញដល់កន្លែងកើតហេតុ បានបញ្ជាក់ថាឈ្មោះ **ស្រី សាម៉ុល** អនុប្រធានគណៈកម្មការការិយាល័យ លេខ០០៥២ របស់ភូមិបន្ទាយក្រាំង ឃុំ ត្រូវពិតដែល បានច្បូតសន្លឹកឆ្នោត ដើម្បីអោយងាយស្រួលក្នុងការរៀបសន្លឹកឆ្នោតជាជុំ ២៥ សន្លឹក ហើយបានធ្វើអោយរហែកដោយអចេតនា នូវសន្លឹកឆ្នោតមួយសន្លឹក ដោយមិនដឹងថាបោះឆ្នោតអោយគណបក្សណាផង ។

-ដោយយល់ឃើញថា : នៅពេលរាប់សន្លឹកឆ្នោត ដែលរហែក ឃើញនៅការិយាល័យ ០០៥១ ហើយលោកលើកបង្ហាញដល់គណៈកម្មការ ឃើញថាសន្លឹកឆ្នោតរហែកចំលេខ ៣៤ និងលេខ ៣៥ ។ គណៈកម្មការរាប់សន្លឹកឆ្នោតបានយកភាគចាត់ទុកសន្លឹកឆ្នោតនោះជាសន្លឹកឆ្នោតមិនបានការ ។

-ដោយយល់ឃើញថា : ពាក្យបណ្តឹងនេះគ្មានធាតុការណ៍គ្រប់គ្រាន់ ដើម្បីបើកសវនាការ តាមមាត្រា ១១៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គប្បីក្រុមប្រឹក្សាធម្មនុញ្ញ សំរេចបដិសេធពុំទទួលពាក្យបណ្តឹងតវ៉ានេះ ។

-ដោយយល់ឃើញថា : សេចក្តីសំរេចលេខ ០៨-១៧១៣/៩៨ គជប ចុះថ្ងៃទី១១ ខែ សីហា ឆ្នាំ ១៩៩៨ របស់គណៈកម្មាធិការរៀបចំការបោះឆ្នោត មានលក្ខណៈត្រឹមត្រូវ ។

**សំរេច**

១-បដិសេធពាក្យបណ្តឹងជំទាស់លេខ ១៦២/៩៨ នគក របស់គណបក្សហ៊្វុនស៊ិនប៉ិច ចុះថ្ងៃទី១១ ខែ សីហា ឆ្នាំ ១៩៩៨ ទាក់ទងនឹងសេចក្តីសំរេច លេខ ០៨/១៧១៣/៩៨ គជប ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៨ ដែលបដិសេធពាក្យបណ្តឹងលេខ ០៣៧/៩៨ ចុះថ្ងៃ ទី០៥ ខែ សីហា ឆ្នាំ ១៩៩៨ ដែលប្តឹងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឃុំបន្ទាយក្រាំង ស្រុក កំពង់រោទិ៍ ខេត្តស្វាយរៀង រហែកចោលសន្លឹកឆ្នោតមួយសន្លឹក ដែលប្រជាពលរដ្ឋគូសអោយ គណបក្ស ហ៊្វុនស៊ិនប៉ិច ។

២-តម្កល់សេចក្តីសំរេចរបស់គណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត ដោយបញ្ជាក់មូលហេតុបន្ថែមថា គណៈកម្មការឃុំ រៀបចំការបោះឆ្នោត ឃុំបន្ទាយក្រាំង មិនបានរហែកទេ ហើយការរហែកដោយអចេតនា នូវសន្លឹកឆ្នោតមួយសន្លឹកនោះ គឺអាស្រ័យដោយលោកអនុប្រធានការិយាល័យបោះឆ្នោត ភូមិបន្ទាយក្រាំង ពេលលោកច្បូតសន្លឹកឆ្នោតតំរៀបក្នុងមួយជុំ ២៥ សន្លឹក ។

៣-សេចក្តីសំរេចនេះធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៨ នាសម័យប្រជុំពេញអង្គ ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសំរេចស្ថាពរបិទផ្លូវតវ៉ា ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ
ហត្ថលេខា និងត្រា
**ចាន់ សុខ**

ដកស្រង់ត្រឹមត្រូវតាមច្បាប់ដើម
លេខាកត់ត្រា
**ម៉ែន គីមលី**